# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណាំងខាងសាសនា និង អក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ លោក ភិយ - ប៊ុក
ក្រុមការ នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកសាសនាៈ ព្រះទេពសត្ថា ស្មរ - ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| លោក ភិយ ,, ក្រុមការ | ឧភទមហេត្ថុះគន្ធិ (តមក) | ៤៨១ |
| — — | ប្រវត្តិសាស្ត្រនៃសុីវិល្បខ្មែរសម័យបុរាណ (តមក) | ៤៨៨ |
| ក្រុមជំនុំវប្បធម៌ | សព្ទបារាំងប្រែជាខ្មែរ ញ៉ាក - ថែម រួបរួម (តមក) | ៤៩៣ |
| លោកសាង - សាភិត លេខានុការ | រឿងត្រៃគភូមា (តមក) | ៥០០ |
| អ្នកឧកញ៉ាវិបុលរាជសេនា នូ - កន | រឿងសាមកុក (តមក) | ៥០៧ |
| — ទេពពិទូរ ឈឹម - ក្រសេម | ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) | ៥១៤ |
| ក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ | សារពាវត្ថុបាយន ខេយ៉ុ ខ្វង-ត្អិច តែង | ៥១៩ |
| លោក ផេង - ជីវ សាស្ត្រាចារ្យ | បក្សីចិត្ត រឿងព្រេងប្រទេសរូម៉ានី | ៥២៧ |

ផ្នែកសាសនា

| | | |
|---|---|---|
| លោក ភិយ - ប៊ុក ក្រុមការ | គន្ធិអាសុីទ្វីប (តមក) | ៥៣៣ |
| ព្រះទេពមុនី យូរ - ប៊ុណ្ណ | ពលកថា | ៥៣៦ |

កំណត់ទំនីប្រវត្តិការណ៍

| | | |
|---|---|---|
| ព្រះទេពសត្ថា ស្មរ - ហាយ | ពិធីបុណ្យស្រង់ទឹក សម្ដេចព្រះមហាសុមេធាធិបតី ជួន - ណាត (ត - ចប់) | ៥៤៥ |
| ក្រសួងធម្មការ | បញ្ជីកាយ តាមបៅអធិការនៃលតាំងថ្មី (តមក) | ៥៥៨ |

## ព្រះទេពមុនី យូរ – ប៉ុណ្ណ

ក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្តីគោរព) ។

វេលានេះ នឹងស្រង់យកពលធម៌ដែលព្រះសម្ពុទ្ធជាបរមគ្រូយើង សំដែងទុកក្នុងសុត្តន្តបិដក មកអធិប្បាយជាផ្លូវធម៌ខ្លះ ផ្លូវលោកខ្លះ តាមសមគួរដូចតទៅនេះ ៖

មនុស្សគ្រប់ជាតិគ្រប់ភាសា ដែលកើតមកក្នុងលោកនេះ សុទ្ធតែមានកិច្ចការគួរប្រកបគួរប្រតិបត្តិ ដែលជាផ្លូវធម៌ផ្លូវសាសនា ឬក៏ផ្លូវលោក ៗ ឯកិច្ចការដែលគួរប្រកបគួរប្រតិបត្តិនោះ មានច្រើនស្ថាន គឺតូចខ្លះ ធំខ្លះ ថោកទាបខ្លះ ឧត្តមខ្លះ លំបាកខ្លះ ងាយខ្លះ ៗ អ្នកប្រកបកិច្ចការគ្រប់ចំពូកនោះ ត្រូវអាស្រ័យកំឡាំងជាប្រមុខ, បើមិនមានកំឡាំងហើយពុំអាចនឹងប្រកបកិច្ចការនោះ ៗ បានឡើយ ។ កំឡាំងនេះជាធម្មជាតិសំខាន់បំផុតក្នុងកិច្ចការគ្រប់យ៉ាង ព្រោះហេតុនោះ

បុគ្គលគួរទំនុកបំរុងរក្សាកំឡាំងកាយឲ្យរឹងប៉ឹង សម្រាប់ប្រកបកិច្ចការតាមនាទីរបស់ខ្លួន ។ កំឡាំងកាយជាធម្មជាតិសំខាន់ក៏ពិត ប៉ុន្តែបើមិនមានកំឡាំងចិត្តជួយអមផង កិច្ចការនោះៗ ក៏មិនបានសម្រេចប្រយោជន៍ដ៏ធំទូលាយប៉ុន្មាន ព្រោះកំឡាំងកាយនឹងកំឡាំងចិត្តទាំងពីរនេះអាស្រ័យគ្នាខ្វះណាមួយពុំបាន បើមានគ្រប់លក្ខណៈទាំងពីរស្ថានក្នុងបុគ្គលណាហើយ បុគ្គលនោះទើបមានសមត្ថភាពអាចបំពេញប្រយោជន៍សព្វគ្រប់បាន ។

មួយទៀត ចិត្តនេះបើមិនបានទទួលការអប់រំសេចក្ដីល្អទុកទេ ក៏មិនមានគោលអ្វីដ៏សំខាន់ជាគ្រឿងទំនុកបំរុងកាយ ឬ ឥស្សរភាពបានឡើយ ។ បុគ្គលដែលនឹងឡើងទៅកាន់ឋានខ្ពស់បាន ក៏ព្រោះអាស្រ័យការអប់រំចិត្តគំនិតឲ្យប្រព្រឹត្តទៅក្នុងផ្លូវល្អ ប្រកបដោយប្រាជ្ញាដ៏ឈ្លាស់ រើសរកផ្លូវត្រូវនឹងផ្លូវមិនគួរ ឲ្យសមតាមកាលៈទេសៈ; បើបណ្ដែតបណ្ដោយទៅតាមទំនើងចិត្តហើយ មុខជាសេចក្ដីអាក្រក់ទង់ទាញទំលាក់ទៅកាន់ទីថោកទាបពុំខាន ។

បុគ្គលដែលមានចិត្តអប់រំល្អហើយ រមែងនាំសេចក្ដីល្អមកដល់ខ្លួនគឺល្អជាងសេចក្ដីល្អដែលមាតាបិតាញាតិមិត្របងប្អូនផ្គត់ផ្គង់ឲ្យទៅទៀត ។ បើចិត្តប្រាសចាកសេចក្ដីអប់រំហើយក៏រមែងនាំឲ្យកើតសេចក្ដីវិនាសផ្សេងៗ ។

មួយវិញទៀត ការដែលនឹងអប់រំចិត្តឲ្យមានកំឡាំងក្លាហានគួរដល់ការងារនោះ ត្រូវអាស្រ័យសេចក្ដីអប់រំក្នុងធម៌, ព្រោះធម៌ជាគ្រឿងចង្អុល

ប្រាប់ផ្លូវឲ្យដឹងច្បាស់ ខុសត្រូវ ល្អអាក្រក់ បុណ្យបាប គុណទោស ។ ព្រោះហេតុនោះ ជនអ្នកស្រឡាញ់សេចក្ដីល្អ គួរអប់រំកំលាំងចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅតាមធម៌ ១ពួក ដែលជាពាក្យប្រៀនប្រដៅក្នុងព្រះពុទ្ធ-សាសនា ហៅថា ពលធម៌ មាននៅក្នុងពួកពោធិបក្ខិយធម៌ (ធម៌កើតមានក្នុងចំណែកនៃការត្រាស់ដឹង) ទុកជាគ្រឿងអប់រំចិត្តឲ្យមានសមត្ថ-ភាពក្នុងការប្រតិបត្តិ ។ ពលធម៌នោះ មាន ៥ យ៉ាងគឺ: សទ្ធាពល:១ វីរិយពល:១ សតិពល:១ សមាធិពល:១ បញ្ញាពល:១ ។

**១ សទ្ធាពល:** ប្រែថា "កំលាំងគឺសទ្ធា" ។ ការប្រតិបត្តិធម៌ជាពាក្យប្រៀនប្រដៅក្នុងព្រះពុទ្ធសាសនា ឬប្រកបកិច្ចការអ្វីមួយជាប្រ-យោជន៍ក្នុងបច្ចុប្បន្ននេះ, ខាងដើមត្រូវមានសទ្ធាជាមូល ។ ពាក្យថាសទ្ធានេះ ជាសំដីដែលមហាជនធ្លាប់ឮចុកត្រចៀកមកហើយ, តែបើទុកជាដូច្នោះ ក៏នៅតែមានពួកជនខ្លះ ពុំទាន់ចូលចិត្តច្បាស់លាស់នៅឡើយ ហេតុនេះ សូមអធិប្បាយពាក្យថា សទ្ធា នេះតទៅ ។ ដូចម្ដេចហៅថា សទ្ធា? សទ្ធា ប្រែថា "ធម្មជាតិមិននាំកើតញាប់ញ័រក្នុងសភាពដែលមិនគួរជឿ" ដូចជឿដោយគេប្រាប់ពន្យល់ថា សេចក្ដីសុខទុក្ខចំរើនវិនាសបានមកពីហេតុខាងក្រៅ មានការបន់ស្រន់បួងសួងទេព្ដាអារក្សអ្នកតាជាដើម ឬជឿដោយសេចក្ដីល្ងង់ ឬក៏កាន់ច្រឡំព្រោះមិនមានប្រាជ្ញាត្រិះរិះឲ្យឃើញហេតុផលជាមុនសិន ហើយកាន់តាមប្រព្រឹត្ត

តាមទៅ, ជឿយ៉ាងនេះមិនហៅថាសទ្ធាក្នុងទីនេះទេ ព្រោះជឿដោយគាន់ប្រថ្នំ ៗ ជនអ្នកមានសទ្ធា មុននឹងធ្វើអ្វីនឹងប្រព្រឹត្តអ្វី គួរពិចារណាឲ្យឃើញហេតុផលជាក់លាក់សិនហើយសឹមជឿ កុំជឿតាលតែស្តុខស្តកទគត់និតទាញមកវិញមិនបាន ៗ ព្រោះព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងថា សទ្ធានឹងបញ្ញាជាគូគា បើមានតែសទ្ធាមិនមានបញ្ញា នឹងប្រគាន់ជឿទៅលើខុសពុំបានសម្រេចប្រយោជន៍ ៗ សទ្ធាទុកដូចជាពូជ, បញ្ញាទុកដូចជាផែនដី, កាលបើគេយកពូជទៅសាបព្រោះបណ្ដុះដាំលើផែនដីឬក្រួសថ្មដែលជាធម្មជាតិឥតមានដីជាតិ ពូជនោះក៏ពុំអាចនឹងដុះមានពន្លកដើមផងបានឡើយ ព្រោះបណ្ដុះដាំទៅលើធម្មជាតិដែលឥតមានដីជាតិ ៗ លុះណាតែយកពូជនោះទៅបណ្ដុះដាំលើផែនដីមានដីជាតិល្អ ទើបពូជនោះនឹងមានពន្លកដុះលូតលាស់ទៅបាន យ៉ាងណាមិញ; សទ្ធាក៏ដូច្នោះដែរ លុះណាតែប្រកបដោយបញ្ញាផង ទើបសទ្ធានោះនឹងមានកំឡាំងមិនងាកបែរបេរទៅរកផ្លូវខុសបាន ៗ

មួយទៀត សទ្ធាទុកដូចជាទ្រព្យដ៏ប្រសើរ, មានពុទ្ធភាសិតថា **សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ** "សទ្ធាជាទ្រព្យដ៏ប្រសើររបស់បុរសក្នុងលោកនេះ" ៗ

ទ្រព្យទាំងអស់ក្នុងលោកមានមាសប្រាក់ជាដើម សុទ្ធតែជារបស់តែងមានសេចក្ដីវិនាសអន្តរាយទៅដោយហេតុផ្សេង ៗ មានចោរលួចភ្លើង

នេះជាដើម ជាទ្រព្យមិននៅក្នុងអំណាចបង្គាប់បញ្ជារបស់ខ្លួនឡើយ មានតែនាំខ្លួនឲ្យដល់នូវសេចក្ដីទុក្ខព្រួយលំបាកជានិច្ច, អ្នកប្រាជ្ញខាងផ្លូវធម៌លោកមិនត្រូវការចង់បានពេកឡើយ ។

ចំណែកទ្រព្យគឺសទ្ធានេះ ជាធម្មជាតិប្រសើរបំផុត ជារបស់មានខ្លឹម មិនពុកផុយរលួយទៅដោយហេតុផ្សេងៗ ទោះចោរក៏លួចយកពុំបាន ជាទ្រព្យជាទីពេញចិត្ត គាប់ចិត្តរបស់អ្នកប្រាជ្ញ ជាទ្រព្យសម្រាប់ទិញយកអស្សទ្ធិយធម៌ គឺសេចក្ដីមិនជឿនោះចោលចេញពីសន្ដាន ។

សទ្ធានេះមាន ៤ យ៉ាងគឺ

១ – ជឿកម្ម (កម្មសទ្ធា)

២ – ជឿផលរបស់កម្ម (វិបាកសទ្ធា)

៣ – ជឿថាសត្វមានកម្មជារបស់ខ្លួន (កម្មស្សកតាសទ្ធា)

៤ – ជឿប្រាជ្ញត្រាស់ដឹងព្រះតថាគត (តថាគតពោធិសទ្ធា) ។

ក្នុងទីនេះនឹងលើកយកតែសទ្ធាពីរយ៉ាងខាងចុងមកអធិប្បាយ ។

**ជឿថាសត្វមានកម្មជារបស់ខ្លួន** នោះគឺ ជឿថាធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ។ សេចក្ដីនេះគប្បីឃើញនូវអំពើរបស់ខ្លួននឹងអ្នកដទៃ ដែលមានអំណោយផលឲ្យឃើញប្រាកដ ដូចជនអ្នកមានសទ្ធាឲ្យនូវវត្ថុអ្វីៗដល់គេ បើទុកជាមិនបានវត្ថុអ្វីជាទីគាប់ចិត្តមកវិញទេ ក៏គង់បានពរសព្ទសាធុការអំពីបដិគ្គាហកក្នុងបច្ចុប្បន្ននេះមកវិញដែរ; នេះជា

ចំណែកខាងល្អ ដែលហៅថាកុសលកម្ម ៗ បើខាងអាក្រក់វិញ ដូចយ៉ាងមនុស្សប្រព្រឹត្តធ្វើចោរកម្ម មានលួចប្លន់ឆក់ដណ្តើមយកទ្រព្យគេជាដើម រដ្ឋការចាប់យកមកវាយតប់ធាក់ដាក់គុកដាក់ច្រវាក់ ធ្វើតាមទោសដែលខ្លួនប្រព្រឹត្តនេះ, ជាអំពើអាក្រក់ដែលហៅថា អកុសលកម្ម ៗ កម្មទាំងពីរយ៉ាងនេះ ជួនកាលឲ្យផលក្នុងបច្ចុប្បន្ននេះភ្លាមៗក៏មាន ជួនកាលឲ្យផលទៅបរលោកក៏មាន; ប៉ុន្តែកម្មទាំងពីរយ៉ាងនេះឲ្យផលមិនស្មើគ្នាទេ ដូចពុទ្ធភាសិតថា:

ន ហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ
អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគតឹ

"ធម៌ពីរយ៉ាងគឺបុណ្យនឹងបាប មានផលមិនស្មើគ្នាទេ បាបរមែងនាំសត្វឲ្យទៅកើតក្នុងនរក បុណ្យរមែងនាំសត្វឲ្យទៅកើតក្នុងសុគតិភព ៗ

មួយទៀត មានបុគ្គលពួកខ្លះក្នុងលោកនេះ ធ្វើអំពើល្អក្តីអាក្រក់ក្តី, ប៉ុន្តែអំពើនោះមិនទាន់ឲ្យផល ដោយមានហេតុដទៃមកស្ទះបិទបាំងពាំងផ្លូវ មិនចេញមុខឲ្យឃើញប្រាកដ, ក៏យល់ថាសេចក្តីល្អអាក្រក់មិនឲ្យផល; ម្លោះហើយក៏លែងជឿលែងធ្វើលែងប្រព្រឹត្តតាមផ្លូវត្រូវទៅវិញក៏មាន; បើតាមសេចក្តីពិត មិនមែនដូច្នោះទេ យូរឆាប់គង់តែអំពើនោះឲ្យផលពុំខាន; សមដូចពុទ្ធភាសិតថា:

**បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ**
**យទា ច បច្ចតី បាបំ អថ បាបានិ បស្សតិ**

*" បុគ្គលអ្នកធ្វើនូវអំពើអាក្រក់ ឃើញតែសេចក្ដីចំរើន កំណត់ត្រឹមពេលដែលបាបមិនទាន់ឲ្យផល, លុះដល់ពេលណាបាបឲ្យផល គេទើបចួបប្រទះនូវបាបទាំងឡាយក្នុងពេលនោះ "* ។

**ភទ្រោបិ បស្សតី បាបំ យាវ ភទ្រំ ន បច្ចតិ**
**យទា ច បច្ចតី ភទ្រំ អថ ភទ្រានិ បស្សតិ**

*" បុគ្គលអ្នកធ្វើនូវសេចក្ដីល្អ ចួបប្រទះតែសេចក្ដីអាក្រក់ កំណត់ត្រឹមពេលដែលសេចក្ដីល្អមិនទាន់ឲ្យផល, លុះដល់ពេលណាសេចក្ដីល្អឲ្យផល គេទើបចួបប្រទះនូវសេចក្ដីសុខក្នុងពេលនោះ "* ។

*ពុទ្ធភាសិតនេះ បំភ្លឺឲ្យឃើញថា អំពើល្អក្ដីអាក្រក់ក្ដី ដែលបុគ្គលធ្វើហើយ ចួនកាលឲ្យផលភ្លាមៗ ចួនកាលក៏ពុំទាន់ឲ្យផល ដោយមានហេតុដទៃមកស្ទះបិទខ្ទប់មិនចេញមុខឲ្យឃើញប្រាកដ ; ប៉ុន្តែមុខជានឹងមានឱកាសណាមួយនឹងឲ្យផលពុំខាន* ។

*មានពុទ្ធភាសិតមួយបែបទៀតថា* **សព្វេ សត្តា កម្មស្សកា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា យំ កម្មំ ករិស្សន្តិ កល្យាណំ វា បាបកំ វា តស្ស ទាយាទា ភវិស្សន្តិ**

“សព្វសត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាទ្រព្យសំបាច់ ឬជាមត៌ក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពឹងអាស្រ័យ ទោះសត្វទាំងនោះធ្វើកម្មណា ជាកម្មល្អក្តី អាក្រក់ក្តី ត្រូវជាអ្នកទទួលនូវផលនៃកម្មនោះ” ។

ព្រោះហេតុនោះ ជនអ្នកមានសទ្ធាគួរមានសេចក្តីជឿថា សេចក្តីល្អអាក្រក់បានមកពីហេតុ គឺអំពើដែលខ្លួនធ្វើ ធ្វើយ៉ាងណា ត្រូវទទួលអំណោយផលយ៉ាងនោះ មិនខុសពីដំណើរអំពើដើម ; យ៉ាងនេះហៅថា “ជឿថាសត្វមានកម្មជារបស់ខ្លួន” ។

**ជឿប្រាជ្ញាត្រាស់ដឹងរបស់ព្រះតថាគតនោះ គឺៈ** សទ្ធាដែលជឿនូវការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធថា ព្រះពុទ្ធជាម្ចាស់បានត្រាស់ឡើងក្នុងលោកនេះ ទ្រង់មានប្រាជ្ញាជាអស្ចារ្យជាងមនុស្សសាមញ្ញ រកបុគ្គលណាស្មើគ្មាន, ព្រះអង្គឆ្ងាយចាកកិលេសហើយ, ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ចំពោះព្រះអង្គ, ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ, ព្រះអង្គមានដំណើរល្អ, ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក, ព្រះអង្គប្រសើរដោយគុណមានសីលជាដើម, ព្រះអង្គជានាយសារថីទូន្មាននូវបុរសដែលគួរទូន្មាន, ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ, ព្រះអង្គត្រាស់ដឹងនូវអរិយសច្ច ៤ ហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង, ព្រះអង្គមិនត្រឡប់កើតក្នុងភពថ្មីទៀត, ធម៌ឯណាដែលមានប្រាកដឡើងហើយ ធម៌នោះមិនកំបាំងនឹងញាណរបស់ព្រះអង្គឡើយ, ធម៌មានត្រឹម

ណា ប្រាជ្ញាញាណក៏មានត្រឹមណោះ, ព្រះអង្គមិនខ្វះប្រាជ្ញាត្រាស់ដឹងនូវធម៌ទាំងពួងឡើយ ។ សមដូចពុទ្ធភាសិតក្នុងគម្ពីរខុទ្ទកនិកាយបដិសម្ភិទាមគ្គថា: **យាវតកំ ញេយ្យំ, តាវតកំ ញាណំ, យាវតកំ ញាណំ, តាវតកំ ញេយ្យំ, ញេយ្យបរិយន្តិកំ ញាណំ, ញាណបរិយន្តិកំ ញេយ្យំ** "ធម៌ដែលព្រះសព្វញ្ញុពុទ្ធគប្បីជ្រាបត្រឹមណា ប្រាជ្ញាញាណក៏មានត្រឹមណោះ, ប្រាជ្ញាញាណមានត្រឹមណា ធម៌ដែលព្រះអង្គគប្បីជ្រាបក៏មានត្រឹមណោះ, ប្រាជ្ញាញាណមានត្រឹមទីបំផុតនៃធម៌ដែលព្រះអង្គគប្បីជ្រាប ធម៌ដែលព្រះអង្គគប្បីជ្រាបមានត្រឹមទីបំផុតនៃប្រាជ្ញាញាណ គឺថាធម៌នឹងប្រាជ្ញាញាណមិនលើសមិនខ្វះគ្នា" ។

ការត្រាស់ដឹងរបស់ព្រះសព្វញ្ញុពុទ្ធនេះ ជាអស្ចារ្យប្លែកជាងមនុស្សសាមញ្ញ, កាលបើត្រាស់ដឹងធម៌ណាហើយ ធម៌នោះជាធម៌ពិតធម៌មែន ហើយព្រះអង្គមិនលាក់ទុកដឹងតែមួយព្រះអង្គឯង ទ្រង់សំដែងពន្យល់ដល់សព្វសត្វឲ្យប្រតិបត្តិតាម យល់តាមដូចព្រះអង្គដែរ ។

ព្រោះហេតុនោះ យើងជាពុទ្ធមាមកជន គួរជឿចំពោះការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធដូចបានពោលមកខាងលើនេះ ហើយកាន់តាមប្រព្រឹត្តតាមពាក្យប្រៀនប្រដៅដែលទ្រង់សំដែងទុកមក ដើម្បីនឹងកសាងកំឡាំងកាយកំឡាំងចិត្តឲ្យរឹងប៉ុងជាងធម្មតា; ជឿយ៉ាងនេះហៅថា "ជឿប្រាជ្ញាត្រាស់ដឹងរបស់ព្រះតថាគត" ។

(មានត)

## ពលកថា

# ព្រះទេពមុនី យូរ - ប៉ុណ្ណ

*ក្រុមជំនុំព្រះត្រៃបិដក នៅក្នុងសាសនបណ្ឌិត្យ ប្រែរៀបរៀង*

(ត - ចប់)

---

ជនអ្នកមានសទ្ធា រមែងបានអានិសង្ស ៥ យ៉ាងគឺ :–

១ – បឋមំ អនុកម្បន្តិ សប្បុរសទាំងឡាយតែងអនុគ្រោះដល់អ្នកមានសទ្ធាមុនគេ ។

២ – បឋមំ ឧបសង្កមន្តិ សប្បុរសទាំងឡាយតែងចូលទៅរកអ្នកមានសទ្ធាមុនគេ ។

៣ – បឋមំ បដិគ្គណ្ហន្តិ សប្បុរសទាំងឡាយតែងទទួលយកទេយ្យវត្ថុរបស់ជនអ្នកមានសទ្ធាមុនគេ ។

៤ – បឋមំ ធម្មំ ទេសេន្តិ សប្បុរសទាំងឡាយរមែងសំដែងធម៌ដល់ជនអ្នកមានសទ្ធាមុនគេ ។

៥ – សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ជនអ្នកមានសទ្ធានោះលុះធ្វើមរណកាលហើយ រមែងទៅកើតក្នុងសុគតិភពគឺឋានសួគ៌ ។

ពោលមកប៉ុណ្ណេះ ហៅថា សទ្ធាពលៈ ។

៣) **វីរិយពល:** ប្រែថា "កំឡាំងគឺសេចក្ដីព្យាយាម" ។ សេចក្ដីព្យាយាមនេះជាគុណជាតិមួយ៉ាង ដែលយឹតយោងចិត្តឲ្យមានកំឡាំងក្នុងការប្រព្រឹត្តធម៌ ឬប្រកបការងារគ្រប់យ៉ាង, បើទុកជាមានជំនឿយ៉ាងណាក៏ដោយ តែបើខ្វះសេចក្ដីព្យាយាមហើយ ការជឿនោះ ក៏មិនបានកំឡាំងប៉ុន្មាន ។

សេចក្ដីព្យាយាមនេះ បើពោលដោយសង្ខេបមានពីរយ៉ាងគឺ:

១– **បហាន:** ព្យាយាមលះសេចក្ដីអាក្រក់កុំឲ្យកើតឡើងក្នុងសន្ដាន ។

២– **ភាវនា** . ព្យាយាមធ្វើកុសលឲ្យកើតឲ្យមានឡើងក្នុងសន្ដាន ។

សេចក្ដីព្យាយាមនេះ កាលបើបុគ្គលបានធ្វើហើយ ប៉ុន្តែមិនចេះរក្សាសេចក្ដីល្អទុក, សេចក្ដីល្អនោះ ក៏នឹងវិនាសទៅវិញ, ព្រោះសេចក្ដីល្អមិនមែនជារបស់គួរធ្វើម្ដងម្កាលឡើយ គួរធ្វើជានិច្ច ទើបឈ្មោះថាមានសេចក្ដីល្អប្រចាំនៅក្នុងសន្ដាន ឬក៏ព្យាយាមរក្សាសេចក្ដីល្អដែលបានធ្វើម្ដងនោះ ហើយមិនធ្វើតទៅទៀត សេចក្ដីល្អនោះក៏ខ្សោយកំឡាំងថយតិចទៅវិញ. កាលបើសេចក្ដីព្យាយាមមានកំឡាំងមាំមួនហើយ ក៏រមែងនាំសន្ដានប្រឡាយហូរទៅរកសេចក្ដីចំរើន, សូម្បីការងារឬផ្លូវប្រតិបត្តិនោះ នោះ

ក្រលំបាកយ៉ាងណាក៏ដោយ គង់បានសម្រេចដូចបំណង ។ សូមទាញឧទាហរណ៍មកបញ្ជាក់ឲ្យឃើញកំឡាំងនៃសេចក្ដីព្យាយាម ; ដូចមហាសមុទ្រដែលមើលកោះមើលត្រើយមិនឃើញ ផុតវិស័យមនុស្សសាមញ្ញនឹងគិតលៃលកកេប្រយោជន៍ឲ្យកើតដល់ខ្លួនមិនបាន, តែគង់មានមនុស្សអ្នកមានគំនិតប្រាជ្ញា អាចគិតឃើញ គេធ្វើនាវាធំតូចប្រកបដោយក្ដោង ឬគ្រឿងចក្រគ្រឿងយន្ត ហើយផ្ទុកទំនិញគ្រប់យ៉ាង បើកកាត់ឆ្លងទៅមកលក់ដូរគ្រប់ប្រទេសក្នុងលោក យកមាសប្រាក់ស្ដុកស្ដម្ភមកជាប្រយោជន៍ខ្លួន ឬយកមកកសាងប្រទេសរបស់គេ ឲ្យទៅជាអារ្យប្រទេសបាន ។

មួយទៀត ដូចយ៉ាងមនុស្សជាន់ខ្ពស់ក្ដី ស្ថានសួគ៌ក្ដី ស្ថានព្រហ្មក្ដី ព្រះនិព្វានក្ដី សុទ្ធតែជាកន្លែងជាន់ខ្ពស់ គេក្របានចួបប្រទះ ក្របានទៅកើតណាស់ ; តែបើទុកជាដូច្នោះ ក៏គង់មានបុគ្គលអ្នកព្យាយាមខំប្រឹងធ្វើប្រឹងប្រព្រឹត្តត្រាតែបានទៅកើតនៅទៅកប់មិនអស់, មើលចុះដូចយ៉ាងព្រះមហាក្សត្រនឹងមន្ត្រីសេដ្ឋីគហបតីតូចធំ និងពួកទេវតា ពួកព្រហ្ម ឬព្រះអរហន្តទាំងឡាយមានព្រះពុទ្ធជាដើម ដែលនឹងបានសម្រេចដល់ឋានតាមលំដាប់ទាំងនោះ ក៏ព្រោះសេចក្ដីព្យាយាមអប់រំកំឡាំងចិត្តឲ្យប្រព្រឹត្តទៅក្នុងកុសលធម៌តាមជាន់តាមថ្នាក់ដែលគួរធ្វើគួរប្រព្រឹត្តបាន; យ៉ាងនេះហៅថា វីរិយការៈ ។

៣) សតិពលៈ ប្រែថា "កំឡាំងគឺសតិ" ។ សតិនេះ ជាគូគ្នានឹងសម្បជញ្ញៈ, សតិនឹងសម្បជញ្ញៈជាធម៌មានឧបការៈច្រើន ។ សតិប្រែថា "សេចក្ដីរលឹក" ។ សម្បជញ្ញៈ ប្រែថា "សេចក្ដីដឹងខ្លួន" ។ គុណធម៌ទាំងពីរនេះ ប្រព្រឹត្តទៅក្នុងកិច្ចជាមួយគ្នា ផ្សេងគ្នាតែអាការៈ; សតិជាភ្នាក់ងារខាងឯនឹកឃើញក្នុងវេលាដែលធ្វើហើយ និយាយហើយ គិតហើយ, សូម្បីយូរ ៗ ក៏នឹកឃើញបានទាំងអស់ ។ សម្បជញ្ញៈជាភ្នាក់ងារខាងឯដឹងខ្លួនក្នុងវេលាដែលកំពុងធ្វើ កំពុងនិយាយ កំពុងគិត ។ ចិត្តរបស់យើង កាលបើមិនមានសតិសម្បជញ្ញៈគ្រប់គ្រងហើយ តែងតែស្ទុះស្ទាច្ចុច្ចាអន្ទះអន្ទែងទៅរកវិសភាគារម្មណ៍ផ្សេង ៗ តាមតែប្រទះ មិនរើសថាគួរនឹងមិនគួរឡើយ ។ ដូចជារថទឹមដោយសេះដែលមិនមាននាយសារថីបរ សេះចេះតែអូសរថទៅតាមទំនើងចិត្តរបស់វា ស្ទុះទៅផ្ទុសផ្ទាសប៉ះនេះប៉ះនោះហែ ៗ ទៅតាមផ្លូវ ធ្វើឱ្យកើតសេចក្ដីអន្តរាយផ្សេង ៗ យ៉ាងណាមិញ; ឯសេចក្ដីប្រព្រឹត្តរបស់មនុស្សក៏ដូចគ្នា គឺថាមនុស្សម្នាក់ ៗ បើមិនមានសតិសម្បជញ្ញៈហើយ រមែងប្រព្រឹត្តកាយកំហុស ៗ ភ្លាត់ ៗ ធ្វើឱ្យកើតសេចក្ដីអន្តរាយផ្សេង ៗ ដល់ខ្លួននឹងអ្នកដទៃពុំខាន ។ ចំណែកមនុស្សដែលមានសតិសម្បជញ្ញៈវិញ រមែងប្រព្រឹត្តកាយកម្មដែលល្អ ៗ ជាហេតុនាំឱ្យបានសេចក្ដីសុខចំពោះខ្លួននឹងអ្នកដទៃ ; យ៉ាងនេះ ហៅថា សតិពលៈ ។

៤) **សមាធិពលៈ** ប្រែថា "កំឡាំងគឺសមាធិ" ។ សមាធិ ប្រែថា "សភាពនឹងធឹង, ខ្ជាប់ខ្ជួន, មាំមួន" ។ សមាធិនេះ ជាធម៌សម្រាប់ពត់ចិត្តតម្រង់ចិត្តឲ្យតាំងនៅដោយល្អក្នុងអារម្មណ៍តែមួយ ព្រោះចិត្តនេះតែងត្រេកត្រអាលទៅក្នុងអារម្មណ៍ផ្សេងៗ មានរូបារម្មណ៍ជាដើម ។ ចិត្តនេះនៅមិនស្ងៀមទេ, ដូចជាសត្វស្វា ធម្មតាសត្វស្វាជាសត្វពើសណាស់ នៅមិននឹងមិនស្ងៀម ចាប់នេះចាប់នោះតាមតែប្រាថ្នា, កាលបើគេចងដៃជាប់ហើយ ក៏យកជើងទៅលូកចាប់ទៀត, កាលបើជាប់ជើងយកមាត់ទៅខាំទៀត, កាលបើជាប់មាត់ ទំផ្លូលប្រមះនឹងទៀលខ្លួនឲ្យទៅប៉ះនឹងវត្ថុនោះទៀត ធ្វើដូចម្តេចឲ្យតែបានទៅប៉ះពាល់ ព្រោះបើវត្ថុនោះក្តៅត្រូវជាក៏រងទន់ ល្អិតក្រោតក្រោត ក៏មិនធុញទ្រាន់ យ៉ាងណាមិញ; ចិត្តរបស់មនុស្សក៏ដូចគ្នាដែរ, កាលបើមិនមានសមាធិចិត្តនៅគ្រប់គ្រងហើយ ក៏រមែងធ្វេធ្វាស្ទុះស្ទាទៅចុះឡើងសោយយកអារម្មណ៍ផ្សេងៗ តាមតែប្រាថ្នា ធ្វើឲ្យកករល្អក់ ដល់ធម៌ដែលធ្លាប់បានអប់រំទុកមក ។ ព្រោះហេតុនោះ បុគ្គលគួរដឹកនាំចិត្តឲ្យនឹងឲ្យស៊ប់ទៅក្នុងសមាធិធម៌ ទើបជាចិត្តស្ងប់ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ទាំងឡាយមាននីវរណធម៌ជាដើម ហើយក៏បានដល់បឋមជ្ឈាន, ទុតិយជ្ឈាន, តតិយជ្ឈាន តាំងលំដាប់ដល់ចតុត្ថជ្ឈាន ដែលមិនមានទុក្ខមិនមានសុខ មានតែសតិដ៏បរិសុទ្ធដោយឧបេក្ខា ហើយចិត្តក៏ទ្រង់ផុតចាកគតិទាំង ៣ បានដល់ព្រះនិព្វាន គុណមានការកើតសាបតទៅ: យ៉ាងនេះហៅថា សមាធិពលៈ ។

៥ បញ្ញាពលៈ ប្រែថា "កំឡាំងគឺបញ្ញា" ។ បញ្ញានេះជាធម្មជាតិដែលមានប្រចាំនៅក្នុងសត្វតាំងពីកំណើត ទោះបីតិចច្រើនតាមឧបនិស្ស័យដែលបានអប់រំទុកមក ។ បញ្ញានេះជាគុណជាតិមិនញាប់ញ័រក្នុងអវិជ្ជា អាចជួយឧបត្ថម្ភនូវសហជាតធម៌ទាំងពួងឲ្យមានកំឡាំង ហើយញុំាងបុគ្គលឲ្យស្ថិតនៅក្នុងសេចក្ដីសុខគឺព្រះនិព្វាន ។ បញ្ញានេះមានការជួយដោះទុក្ខដោះកុនដែលកើតឡើងក្នុងបច្ចុប្បន្ននេះភ្លាមៗបាន ។ បញ្ញានេះមានការដឹងប្លែកជាងសញ្ញានិងវិញ្ញាណ ។ សញ្ញាត្រាន់តែដឹងនូវអារម្មណ៍មានពណ៌ខៀវលឿងជាដើម, មិនអាចចាក់ធ្លុះនូវត្រៃលក្ខណ៍បានឡើយ ឬក៏ដឹងនូវវត្ថុមានតម្លៃល្អអាក្រក់បានឡើយ ។ វិញ្ញាណដឹងច្បាស់នូវអារម្មណ៍មានពណ៌ខៀវលឿងជាដើមផង ចាក់ធ្លុះនូវត្រៃលក្ខណ៍ផង, តែមិនអាចឲ្យសំរេចមគ្គផលបានឡើយ ។ ឯបញ្ញាអាចដឹងច្បាស់នូវអារម្មណ៍គ្រប់យ៉ាង ទាំងចាក់ធ្លុះនូវត្រៃលក្ខណ៍ ទាំងអាចជ្រោមជ្រែងឲ្យបានសម្រេចមគ្គផលគឺព្រះនិព្វានផង ។

ឯផ្លូវប្រតិបត្តិរបស់បញ្ញា ដែលព្រះពុទ្ធជាអ្នកប្រាជ្ញទ្រង់ត្រាស់សំដែងដោយច្រើននោះ បានខាងបញ្ញាដែលដឹងច្បាស់ក្នុងលក្ខណៈ ៣ យ៉ាងគឺ អនិច្ចតា=សភាពជារបស់មិនទៀង ១, ទុក្ខតា=សភាពជាទុក្ខ ១, អនត្តតា=សភាពមិនមែនជារបស់ខ្លួន ១ ។ ទាំងបីនេះជាផ្លូវប្រតិបត្តិនៃបញ្ញា អាចយល់ច្បាស់នូវការកើតឡើងនិងវិនាសទៅវិញ ហើយអាច

ដាក់ផ្ទះទំលុះទំលាយខ្លួនចេញពីលោភៈ ទោសៈ មោហៈ ឲ្យអស់ទៅ ជាបញ្ញាបរិសុទ្ធផុតចាកកិលេស ហើយធ្វើចិត្តឲ្យអស់ទៅដោយប្រពៃ ។ បញ្ញាចែកចេញជា ២ យ៉ាងគឺ លោកិយបញ្ញា ១ លោកុត្តរបញ្ញា ១ ។ បញ្ញាឈ្លាសវៃក្នុងការស្គាល់ហេតុ-ផល ដើម្បីនាំខ្លួនឲ្យបានសុខស្រួលក្នុងបច្ចុប្បន្ន ហៅថា លោកិយបញ្ញា ។ បញ្ញាដែលខ្ពស់ផុតលោកទាំងបី ហៅថា លោកុត្តរបញ្ញា ។

បញ្ញានេះទុកដូចជាកាំបិតមុតថ្លា សំរាប់កាប់ផ្តាច់នូវព្រៃទ្រុបទ្រុលគឺកិលេសដែលធ្វើចិត្តសត្វឲ្យសៅហ្មង , ឬ ដូចជាប្រទីបសម្រាប់បំភ្លឺក្នុងទីងងឹត ។

ហេតុឲ្យកើតបញ្ញាមាន ៣ យ៉ាងគឺ :

១ – សុតាមយប្បញ្ញា បញ្ញាកើតអំពីការស្ដាប់ ។

២ – ចិន្តាមយប្បញ្ញា បញ្ញាកើតអំពីការគិត ។

៣ ភាវនាមយប្បញ្ញា បញ្ញាកើតអំពីការចំរើនភាវនា ឬការធ្វើឲ្យច្នឹក ។ ទាំង ៣ នេះជាឧបាយធ្វើឲ្យកើតបញ្ញា ។

បុគ្គលអ្នកស្រឡាញ់សេចក្ដីសុខ ចំរើន គួរអប់រំបញ្ញាឲ្យកើតឲ្យមានឡើងក្នុងសន្តាន ដើម្បីនឹងពេញប្រយោជន៍របស់ខ្លួនឲ្យបានគ្រប់គ្រាន់ ទាំងបច្ចុប្បន្ន ទាំងបរលោក ; ពោលមកដោយសង្ខេបប៉ុណ្ណេះ ហៅថាបញ្ញាពលៈ ។ ចប់ភាគ៣.